COMMO T
Trust. Trade. Thrive

# គោលនយោបាយស្ដីពីឯកជនភាព

## សេចក្ដីផ្ដើម

ការការពារឯកជនភាពរបស់អតិថិជន និងការរក្សាទុកព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលដោយសម្ងាត់ គឺជាការសំខាន់បំផុតរបស់ក្រុមហ៊ុន កូម៉ូធី ឯ.ក (តទៅហៅថា COMMO T)។ គោលនយោបាយស្ដីពីឯកជនភាពនេះ (តទៅហៅថា គោលនយោបាយ) បានកំណត់ពីរបៀបដែល COMMO T ប្រមូល និងគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសំខាន់ៗរបស់អតិថិជន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុង គោលនយោបាយនេះ ពាក្យ COMMO T សំដៅទៅលើក្រុមហ៊ុន កូម៉ូធី ឯ.ក និងក្រុមហ៊ុន ឬដៃគូពាក់ព័ន្ធ។

COMMO T ប្រមូលព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសំខាន់ៗរបស់អតិថិជន ដើម្បីផ្ដល់នូវផលិតផល និងសេវាកម្មដែលអតិថិជនបានស្នើសុំ ក៏ដូចជាព័ត៌មានពីផលិតផល និងសេវាកម្មដែលបានផ្ដល់ឱ្យដោយ COMMO T និងតតិយភាគី។ COMMO T អាចប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសំខាន់ៗរបស់អតិថិជន ក្នុងគោលបំណងដើម្បីគ្រប់គ្រងផលិតផល និងសេវាកម្មរបស់ COMMO T ដើម្បីការការពារ និងដើម្បីការគ្រប់គ្រងហានិភ័យ លើកលែងតែមានការអនុញ្ញាតពីអតិថិជន ឱ្យធ្វើការផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងទីផ្សារតែប៉ុណ្ណោះ។ COMMO T ក៏ប្រើព័ត៌មានដែលបានរក្សាទុក ដើម្បីស្វែងរក និងការពារសកម្មភាពខុសច្បាប់។ COMMO T សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នអនុវត្តច្បាប់ផ្សេងៗទៀតដែលតម្រូវដោយច្បាប់។ COMMO T នឹងបង្ហាញព័ត៌មានផ្ទាល់ខ្លួនបុគ្គលដែលពាក់ព័ន្ធទៅនឹងស្ថាប័នក្រៅក្រុមហ៊ុន ដើម្បីជួយ COMMO T ក្នុងការផ្ដល់សេវាកម្ម។ ស្ថាប័នទាំងនោះ ត្រូវបានភ្ជាប់ជាមួយនឹងកាតព្វកិច្ចរក្សាការសម្ងាត់ដែលបានរៀបចំនេះ។ ស្ថាប័នទាំងនោះអាចរួមបញ្ចូលជាមួយនឹងស្ថាប័នក្រៅប្រទេសផងដែរ។

គោលនយោបាយនេះ នឹងត្រូវបានត្រួតពិនិត្យមើលជាប្រចាំដើម្បីពិចារណាលើលក្ខខណ្ឌច្បាប់ និងបច្ចេកវិទ្យាផ្សេងៗ ក៏ដូចជារាល់ការផ្លាស់ប្ដូរទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងដំណើរការប្រតិបត្តិការរបស់ COMMO T ហើយរាល់ការកែប្រែ ឬវិសោធនកម្មទៅលើគោលនយោបាយនេះ នឹងត្រូវបានដាក់បង្ហាញឯកសារថ្មីទៅក្នុងគេហទំព័រនេះ។ រាល់ការប្រើប្រាស់គេហទំព័រនេះបង្ហាញពីការទទួលយក និងទទួលស្គាល់នូវការកែប្រែទាំងអស់នោះរបស់អតិថិជន។ រាល់ទិន្នន័យ និងព័ត៌មានដែលកាន់កាប់ដោយ COMMO T នឹងត្រូវគ្រប់គ្រងដោយគោលនយោបាយ និងបទប្បញ្ញត្តិរបស់ COMMO T។

## ការប្រមូលព័ត៌មានផ្ទាល់ខ្លួនបុគ្គល

### ព័ត៌មានផ្ទាល់ខ្លួនបុគ្គល

ព័ត៌មានផ្ទាល់ខ្លួនបុគ្គល គឺជាព័ត៌មាន ឬមតិទាំងឡាយណារបស់អតិថិជន ដែលមានសមត្ថភាព (ឬសមត្ថភាពដែលសមហេតុផល) ក្នុងការកំណត់អត្តសញ្ញាណរបស់អតិថិជន ទោះបីជាព័ត៌មាន ឬមតិទាំងនោះពិត ឬមិនពិត និងមិនសំដៅលើព័ត៌មានដែលបានកត់ត្រាជាទម្រង់សម្ភារៈក៏ដោយ។ ក្រៅពីនោះ ដើមកំណើត ឬជាតិសាសន៍ គោលគំនិតនយោបាយ ឬសមាជិកភាពក្នុងគណបក្សនយោបាយ ជំនឿសាសនា ឬជំនឿទស្សនវិជ្ជា សមាជិកភាពក្នុងសមាគមពាណិជ្ជកម្ម ឬសហភាពពាណិជ្ជកម្ម ទំនោរផ្លូវភេទ ឬកំណត់ត្រាព្រហ្មទណ្ឌ ក៏ដូចជាព័ត៌មានសុខភាពបុគ្គល ហ្សែន និងព័ត៌មានជីវមាត្រ និងគំរូជីវមាត្រ គឺជាព័ត៌មានផ្ទាល់ខ្លួន និងជាព័ត៌មានសំខាន់។

ជាទូទៅ ព័ត៌មានផ្ទាល់ខ្លួនដែល COMMO T ប្រមូលពីអតិថិជន រួមមាន÷

- **សម្រាប់រូបវន្តបុគ្គល**
  - ឈ្មោះពេញ
  - ឈ្មោះដែលធ្លាប់បានប្រើ ឬផ្លាស់ប្ដូរពីមុន (បើមាន)
  - ភេទ
  - ថ្ងៃខែឆ្នាំកំណើត
  - សញ្ជាតិ
  - លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

- អាជ្ញាធរចេញអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
- កាលបរិច្ឆេទផុតសុពលភាពអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
- អាសយដ្ឋានបច្ចុប្បន្ន
- អាសយដ្ឋានអចិន្ត្រៃយ៍
- លេខទូរសព្ទទំនាក់ទំនង
- សារអេឡិចត្រូនិច
- ព័ត៌មានពីមុខរបរ
- ស្ថានភាពអាពាហ៍ពិពាហ៍
- ព័ត៌មានពីសហព័ទ្ធ
- ព័ត៌មានពីការសិក្សា
- គោលបំណងនៃការវិនិយោគ
- បទពិសោធន៍វិនិយោគ
- ព័ត៌មានពីប្រាក់ចំណូល
- ប្រភពមូលធន
- បុគ្គលទទួលបានផលប្រយោជន៍
- ព័ត៌មានពីគណនីធនាគារ និងប័ណ្ណធនាគារ
- ព័ត៌មានទំនាក់ទំនងក្នុងករណីចាំបាច់
- ការត្រួតពិនិត្យឥណទាន ឬក្ស័យធន
- រាល់ព័ត៌មានដទៃទៀតដែល COMMO T គិតថាចាំបាច់

- **សម្រាប់នីតិបុគ្គល**

- ឈ្មោះនីតិបុគ្គល
- លេខចុះបញ្ជីពាណិជ្ជកម្ម
- កាលបរិច្ឆេទផុតសុពលភាពវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម
- លេខអត្តសញ្ញាណកម្មសារពើពន្ធ
- ប្រភេទក្រុមហ៊ុន
- ប្រភេទអាជីវកម្ម
- អាសយដ្ឋានក្រុមហ៊ុន
- ឈ្មោះរបស់អ្នកតំណាង
- ភេទរបស់អ្នកតំណាង
- ថ្ងៃខែឆ្នាំកំណើតរបស់អ្នកតំណាង
- សញ្ជាតិរបស់អ្នកតំណាង
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកតំណាង
- កាលបរិច្ឆេទផុតសុពលភាពអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកតំណាង
- ស្ថានភាពអាពាហ៍ពិពាហ៍របស់អ្នកតំណាង
- តួនាទីរបស់អ្នកតំណាង
- អាសយដ្ឋានបច្ចុប្បន្នរបស់អ្នកតំណាង
- លេខទូរសព្ទទំនាក់ទំនងរបស់អ្នកតំណាង
- សារអេឡិចត្រូនិចរបស់អ្នកតំណាង
- ដើមទុនចុះបញ្ជី
- ចំណូលចម្បងរបស់អាជីវកម្ម
- ព័ត៌មានពីអភិបាលប្រតិបត្តិ ឬនាយកប្រតិបត្តិ
- ព័ត៌មានពីបុគ្គលជាប់ទាក់ទង
- ព័ត៌មានពីភាគហ៊ុនិក
- ព័ត៌មានពីប្រាក់ចំណេញ
- ប្រភពមូលធន
- ព័ត៌មានពីគណនីធនាគារ និងប័ណ្ណធនាគារ
- ការត្រួតពិនិត្យឥណទាន ឬក្ស័យធន
- គោលបំណងនៃការវិនិយោគ
- បទពិសោធន៍វិនិយោគ
- ព័ត៌មានទំនាក់ទំនងក្នុងករណីចាំបាច់
- រាល់ព័ត៌មានដទៃទៀតដែល COMMO T គិតថាចាំបាច់

COMMO T ត្រូវបានតម្រូវដោយច្បាប់ដើម្បីកំណត់អត្តសញ្ញាណរបស់អតិថិជន ប្រសិនបើអតិថិជនបើកគណនីថ្មី ឬបន្ថែមអ្នកចុះហត្ថលេខាថ្មីទៅកាន់គណនីដែលមានស្រាប់។ COMMO T តម្រូវឱ្យត្រួតពិនិត្យ និងកត់ត្រារាល់ទិន្នន័យព័ត៌មាននៃឯកសារមួយចំនួន។

នៅពេលចាំបាច់ COMMO T ក៏នឹងធ្វើការប្រមូលព័ត៌មានបុគ្គលដូចខាងក្រោមផងដែរ÷

- អ្នកធានា
- ដៃគូ

- អគ្គនាយកក្រុមហ៊ុន និងនិយោជិត
- មន្ត្រីសហករណ៍ និងសមាគម
- ភ្នាក់ងាររបស់អតិថិជន
- ម្ចាស់អត្ថប្រយោជន៍របស់អតិថិជន និង
- បុគ្គលដែលទាក់ទងជាមួយ COMMO T។

COMMO T អាចចាត់វិធានការមួយចំនួនដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលប្រមូលបាន។ ប្រសិនបើអតិថិជនបានផ្តល់ COMMO T នូវព័ត៌មានមិនគ្រប់គ្រាន់ ឬព័ត៌មានដែលមិនត្រឹមត្រូវ COMMO T អាចមិនផ្តល់ឱ្យអតិថិជននូវផលិតផល ឬសេវាកម្មដែលអតិថិជនបានស្នើសុំនោះទេ។

COMMO T ប្រមូលតែព័ត៌មានផ្ទាល់ខ្លួនបុគ្គល នៅពេលដែលចាំបាច់សម្រាប់ COMMO T ដើម្បីអាចផ្តល់ជូននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុដល់អតិថិជន។ COMMO T ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនសម្រាប់៖

- ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អតិថិជន
- ផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មដែលអតិថិជនបានធ្វើការស្នើសុំ
- ជួយ COMMO T តាមដាន វាយតម្លៃ និងអភិវឌ្ឍផលិតផល និងសេវាកម្មរបស់ COMMO T
- ធានានូវការប្រើប្រាស់ដោយមានសុវត្ថិភាពទៅកាន់អតិថិជនរបស់ COMMO T
- លុះត្រាតែមានការអនុញ្ញាតឱ្យ COMMO T ជូនដំណឹងដល់អ្នកអំពីផលិតផល និងសេវាកម្មរបស់ COMMO T និងអាជីវកម្មដែលពាក់ព័ន្ធរបស់ COMMO T និងដៃគូ ហើយធ្វើការកែសម្រួលព័ត៌មានទាំងនោះទៅតាមតម្រូវការ និងការចាប់អារម្មណ៍របស់អតិថិជន
- ឆ្លើយតបទៅនឹងមតិយោបល់ សំណួរ ឬបណ្តឹងណាមួយ
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសទៅកាន់អតិថិជន
- ចូលរួមក្នុងវិនិយោគរបស់តតិយភាគី ឬការវិនិយោគដែលមានសក្តានុពលលើ COMMO T ឬទ្រព្យសកម្មរបស់ក្រុមហ៊ុន
- អនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់របស់ COMMO T តាមច្បាប់ដែលមានជាធរមាន និង
- ចាត់វិធានការដើម្បីស្វែងរក និងការពារការក្លែងបន្លំ បទល្មើស និងសកម្មភាពដទៃទៀតដែលអាចប៉ះពាល់ដល់អាជីវកម្ម ឬផលិតផល និងសេវាកម្មរបស់ COMMO T។

COMMO T អាចធ្វើការប្រមូលទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជនពីអតិថិជនដោយផ្ទាល់ ឬពីប្រភពផ្សេងទៀតដែលអតិថិជនបានអនុញ្ញាត។ ប្រភពផ្សេងទៀតនោះរួមមាន ពីភ្នាក់ងាររបស់អតិថិជន សមាជិកគ្រួសារ មិត្តភ័ក្ត្រ អង្គភាពពាក់ព័ន្ធ ដៃគូ និងផ្នែកផ្សេងៗ។ COMMO T អាចធ្វើការប្រមូលទិន្នន័យពីអតិថិជនដោយអេឡិចត្រូនិច ដូចជានៅពេលដែលអតិថិជនបានចូលមកកាន់គេហទំព័ររបស់ក្រុមហ៊ុនជាដើម។ ជាទៀងទាត់ COMMO T អាចស្នើសុំអតិថិជនផ្តល់នូវព័ត៌មានដោយស្ម័គ្រចិត្តមកកាន់ COMMO T សម្រាប់គោលបំណងទីផ្សារ និងការស្ទង់មតិជាដើម។

## ខូឃីស៍ (COOKIES)

ខូឃីស៍ (Cookies) គឺជាឯកសារទិន្នន័យតូចដែលបានស្នើសុំការអនុញ្ញាតដើម្បីរក្សាទុកនៅក្នុងកុំព្យូទ័ររបស់អតិថិជន ក្នុងគោលបំណងផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់គេហទំព័រ តាមរយៈការអនុញ្ញាតឱ្យអតិថិជនចូលទៅកាន់ផ្នែកសម្រាប់សមាជិករបស់គេហទំព័រ ដោយមិនចាំបាច់ដំណើរការចូលម្តងទៀត។ ប្រសិនបើកុំព្យូទ័ររបស់អតិថិជនបានកំណត់ការអនុញ្ញាត Cookies ឯកសារនោះនឹងបញ្ចូលទៅក្នុងកុំព្យូទ័រ ហើយ Cookies នឹងជួយធ្វើការវិភាគការធ្វើចរាចរណ៍លើគេហទំព័រ ឬឱ្យក្រុមហ៊ុនបានដឹង នៅពេលដែលអតិថិជនបានចូលទៅកាន់គេហទំព័រនោះ។ អតិថិជនអាចធ្វើការកំណត់កម្មវិធីរុករក ដើម្បីជូនដំណឹងដល់អតិថិជននៅពេលដែល Cookies បានអនុញ្ញាត ឬមិនអនុញ្ញាត។

ប្រសិនបើអតិថិជនមិនចង់ទទួលបាន Cookies ទេ កម្មវិធីរុករកភាគច្រើនផ្តល់សិទ្ធិឱ្យអតិថិជនធ្វើការអនុញ្ញាត ឬមិនអនុញ្ញាត Cookies និងក្នុងករណីខ្លះ ក៏នៅតែអាចឱ្យអតិថិជនចូលទៅកាន់គេហទំព័របានដែរ។

Cookies ជួយ COMMO T ផ្តល់គេហទំព័រឱ្យកាន់តែល្អប្រសើរដល់អតិថិជន តាមរយៈការអនុញ្ញាតឱ្យ COMMO T ត្រួតពិនិត្យមើលគេហទំព័រដែលអតិថិជនបានប្រើប្រាស់ និងគិតថាមានអត្ថប្រយោជន៍ និងកែសម្រួលគេហទំព័រដើម្បីស្របទៅតាមតម្រូវការរបស់អតិថិជន ការចូលចិត្ត និងការមិនចូលចិត្តរបស់អតិថិជនតាមរយៈការប្រមូលផ្តុំ និងចងចាំព័ត៌មានអំពីចំណង់ចំណូលចិត្តរបស់អតិថិជន។ COMMO T ក៏អាចប្រមូលព័ត៌មានរបស់កុំព្យូទ័ររបស់អតិថិជន ដូចជាលេខ IP Address ប្រព័ន្ធប្រតិបត្តិការ និងប្រភេទកម្មវិធីដែលអតិថិជនបានប្រើប្រាស់ សម្រាប់ការគ្រប់គ្រងប្រព័ន្ធរបស់ក្រុមហ៊ុន។ នេះគឺជាទិន្នន័យស្ថិតិ អំពីសកម្មភាព និងគំរូនៃការស្វែងរករបស់អតិថិជន ដែលមិនកំណត់អត្តសញ្ញាណរបស់អតិថិជន ឬបុគ្គលណាម្នាក់នោះទេ។ COMMO T អាចបង្ហាញទិន្នន័យដែល COMMO T បានប្រមូលតាមរយៈ Cookies ទៅកាន់ក្រុមហ៊ុនដែលពាក់ព័ន្ធរបស់យើង។

កម្មវិធីស្វែងរកភាគច្រើនផ្តល់សិទ្ធិឱ្យអតិថិជនកែតម្រូវការកំណត់ ដើម្បីលុប Cookies មិនអនុញ្ញាត Cookies ឬទទួលការរំលឹកមុននឹងការដំណើរការរបស់ Cookies បានកំណត់។ សូមកត់សម្គាល់ថា ផ្នែកខ្លះនៃគេហទំព័ររបស់ក្រុមហ៊ុន អាចមិនដំណើរការពេញលេញ ប្រសិនបើអតិថិជនមិនអនុញ្ញាតឱ្យ Cookies ដំណើរការ។

## ការយល់ព្រម

ក្នុងករណីភាគច្រើន COMMO T នឹងទទួលបានការព្រមព្រៀង និងអនុញ្ញាតពីអតិថិជនដើម្បីប្រើប្រាស់ និងបង្ហាញទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជន សម្រាប់គោលបំណងដែល COMMO T មានមុនពេល ឬអំឡុងពេលដែល COMMO T បានប្រមូលវា។ ប្រសិនបើអតិថិជនមិនផ្តល់ការព្រមព្រៀង និងអនុញ្ញាត ឬដកការព្រមព្រៀង និងអនុញ្ញាតពី COMMO T វិញ COMMO T មិនអាចនឹងផ្តល់ផលិតផល ឬសេវាកម្មដែលអតិថិជនបានស្នើសុំនោះទេ។ អតិថិជនអាចស្នើសុំដកការព្រមព្រៀង និងអនុញ្ញាតវិញនៅពេលណាក៏បាន ដោយអនុលោមតាមនីតិវិធីនៃការដកការព្រមព្រៀង និងអនុញ្ញាតរបស់ក្រុមហ៊ុន។

## អនាមិកភាព

ក្នុងករណីខ្លះ COMMO T អាចអនុញ្ញាតឱ្យអតិថិជនទទួលលក្ខខណ្ឌ ក្នុងការប្រើប្រាស់អនាមិកភាព ឬរក្សាការមិនបញ្ចេញអត្តសញ្ញាណរបស់ខ្លួន នៅពេលដែលអតិថិជនធ្វើការទំនាក់ទំនងជាមួយ COMMO T។ COMMO T អាចផ្តល់លក្ខខណ្ឌនេះដល់អតិថិជន តែក្នុងករណីដែលមានភាពជាក់ស្តែងក្នុងការអនុវត្ត ហើយច្បាប់មិនតម្រូវឱ្យ COMMO T ក្នុងការកំណត់អត្តសញ្ញាណរបស់អតិថិជន។

## ការដោះស្រាយពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួនដែលមិនបានស្នើសុំ

ក្នុងករណីដែល COMMO T បានទទួលព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនដែល COMMO T មិនបានធ្វើការស្នើសុំ COMMO T នឹងធ្វើការរក្សាទុកវា ប្រសិនបើ COMMO T បានកំណត់ថា៖

- ព័ត៌មានដែលទទួលបាននោះ គឺចាំបាច់សម្រាប់ COMMO T ដើម្បីធ្វើអាជីវកម្មជាមួយអតិថិជន និង
- អតិថិជនបានយល់ព្រមរួចជាស្រេចទៅលើព័ត៌មានដែលបានប្រមូលមកនោះ ឬវាមិនមានភាពជាក់ស្តែង ឬសមហេតុផលសម្រាប់ COMMO T ក្នុងការទទួលបានការយល់ព្រមពីអតិថិជនក្នុងកាលៈទេសៈណាមួយនោះ។

ក្នុងករណីដែលវាមិនស្ថិតក្នុងលក្ខខណ្ឌណាមួយខាងលើនេះ COMMO T នឹងធ្វើការបំផ្លាញ ឬលុបបំបាត់ការផ្ទៀងផ្ទាត់ព័ត៌មានទាំងនោះ។ ប្រសិនបើព័ត៌មានមិនបានធ្វើការស្នើសុំដែល COMMO T ទទួលបាននោះ ជាព័ត៌មានសំខាន់ COMMO T នឹងស្នើសុំការអនុញ្ញាតពីអតិថិជនដើម្បីរក្សាទុកវា ដោយមិនគិតពីកាលៈទេសៈណាទាំងអស់។

# ការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនបុគ្គល

COMMO T នឹងប្រើប្រាស់ព័ត៌មានរបស់អតិថិជនសម្រាប់គោលបំណងនៃការបើកគណនី និងការថែរក្សាគណនី បញ្ជាក់អត្តសញ្ញាណរបស់អតិថិជន គ្រប់គ្រងប្រវត្តិរូប និងគណនីជួញដូររបស់អតិថិជន និងដើម្បីអនុញ្ញាតឱ្យ COMMO T ផ្តល់ផលិតផល និងសេវាកម្មរបស់ខ្លួនទៅកាន់អតិថិជនតាមរយៈការស្នើសុំពី COMMO T។ ដរាបណាអតិថិជនបានស្នើសុំ COMMO T នឹងធ្វើការទាក់ទងទៅកាន់អតិថិជន ពីព័ត៌មាន និងឱកាសពិសេសដែលពាក់ព័ន្ធទៅនឹងផលិតផលដែលមានស្រាប់ និងផលិតផល និងសេវាកម្មថ្មី ដែល COMMO T គិតថាសាកសមនឹងអតិថិជន។ COMMO T ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនបុគ្គល តែក្នុងករណីចាំបាច់ដើម្បីផ្តល់សេវាកម្មដែលមានគុណភាព និងសុវត្ថិភាពដល់អតិថិជនទេ។ ព័ត៌មាននេះអាចជួយដល់ការធ្វើឱ្យប្រសើរឡើងនៃសេវាកម្ម ផ្លាស់ប្តូរបទពិសោធន៍នៃការរុករក និងអនុញ្ញាតឱ្យ COMMO T ជូនដំណឹងអតិថិជណពីព័ត៌មានបន្ថែមពីផលិតផល សេវាកម្ម ឬការផ្តល់ជូនពិសេសៗ ដែលពាក់ព័ន្ធនឹងអតិថិជន ក៏ដូចជាផលិតផល និងសេវាកម្មដែលអតិថិជនតម្រូវ និងអនុញ្ញាតឱ្យ COMMO T ប្រើប្រាស់ទិន្នន័យនោះ សម្រាប់គោលបំណងនោះ។ ទោះបីជាអតិថិជនមិនតម្រូវឱ្យផ្តល់នូវព័ត៌មានផ្ទាល់ខ្លួនណាមួយមក COMMO T ដែលក្រុមហ៊ុនអាចនឹងធ្វើការស្នើសុំ សូមកត់សម្គាល់ថា ការខកខានមិនបានផ្តល់ដូចការតម្រូវ អាចធ្វើឱ្យ COMMO T មិនអាចបើកគណនីរបស់អតិថិជន ឬផ្តល់ឱ្យអតិថិជននូវសេវាកម្មដែលត្រូវការ។ ខណៈពេលដែល COMMO T ព្យាយាមធានាថារាល់ព័ត៌មានទាំងអស់ដែល COMMO T ទទួលបានពីអតិថិជនគឺជាក់ស្តែង ត្រឹមត្រូវ និងពេញលេញ COMMO T ជម្រុញឱ្យអតិថិជនធ្វើការទាក់ទងមកកាន់ក្រុមហ៊ុនភ្លាម ក្នុងករណីដែលព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនណាមួយមានការប្រែប្រួល។

# ការបង្ហាញនូវព័ត៌មានផ្ទាល់ខ្លួនបុគ្គល

COMMO T មិនលក់ មិនផ្តល់អាជ្ញាប័ណ្ណ មិនជួល ឬមិនបង្ហាញព័ត៌មានផ្ទាល់ខ្លួនបុគ្គលទៅកាន់តតិយភាគីនោះទេ លើកលែងតែត្រូវបានកំណត់នៅក្នុងគោលនយោបាយនេះ។ COMMO T អាចចែករំលែកព័ត៌មានទាំងនេះជាមួយនឹងដៃគូ សាខា និងសម្ព័ន្ធមិត្ត ក្នុងករណីដែលព័ត៌មានទាំងនោះ ត្រូវបានតម្រូវដោយសមហេតុផលដោយដៃគូពាក់ព័ន្ធនោះ ក្នុងគោលបំណងជួញបំពេញមុខងារបន្ថែម ឬជាដៃគូសហការ ដើម្បីផ្តល់ផលិតផល និងសេវាកម្មបន្ថែមផ្សេងទៀត ឬដើម្បីជួយដំណើរការមុខងារផ្ទៃក្នុងមួយចំនួនដូចជាដំណើរការរបស់គណនី ការបំពេញតម្រូវការអតិថិជន សេវាកម្មអតិថិជន ការស្ទង់មតិពេញចិត្តរបស់អតិថិជន ឬសកម្មភាពនៃការប្រមូលទិន្នន័យដទៃទៀត ដែលពាក់ព័ន្ធទៅនឹង អាជីវកម្មរបស់ COMMO T ឬអនុវត្តសកម្មភាពអាជីវកម្មដែលពាក់ព័ន្ធនឹងតម្រូវការរបស់អតិថិជន និងត្រូវបានផ្តល់ជូនតាមរបៀបដែលមានប្រយោជន៍ និងពាក់ព័ន្ធ (លើកលែងតែអតិថិជនបានអនុញ្ញាតឱ្យ COMMO T) និង/ ឬគណនីសេវាកម្មអតិថិជន។ តតិយភាគីទាំងអស់ដែល COMMO T បានចែករំលែកនូវព័ត៌មានផ្ទាល់ខ្លួនបុគ្គល តម្រូវឱ្យការពារព័ត៌មានផ្ទាល់ខ្លួនបុគ្គលទាំងអស់នោះ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិដែលមានជាធរមាន និងក្នុងលក្ខណដែលស្រដៀងនឹងនីតិវិធីដែល COMMO T បានការពារ។ COMMO T នឹងមិនចែករំលែកព័ត៌មានផ្ទាល់ខ្លួនបុគ្គល ជាមួយនឹងតតិយភាគីដែលក្រុមហ៊ុនគិតថានឹងងមិនមានលទ្ធភាព ផ្តល់ជូនអតិថិជននូវកំរិតនៃការការពារដែលតម្រូវនោះទេ។ តតិយភាគី និងដៃគូទាំងនេះរួមមាន÷

- ឈ្មួញកណ្តាល និងភ្នាក់ងារដែលបានទាក់ទងអាជីវកម្មរបស់អតិថិជនមកកាន់ COMMO T
- តតិយភាគី ដែលជាដៃគូអាជីវកម្ម ឬអ្នកផ្តល់គំនិតផ្តួចផ្តើមរួមគ្នារបស់ COMMO T
- សវនកររបស់ COMMO T ដែលបានចាត់តាំងដើម្បីធានានូវតម្លាភាព នៃប្រតិបត្តិការរបស់ COMMO T
- បុគ្គលណាម្នាក់ដែលតំណាងឱ្យអតិថិជន រួមទាំងទីប្រឹក្សាហិរញ្ញវត្ថុ អ្នកស្នើសុំ ភ្នាក់ងារទូទាត់ គណនេយ្យករ ប្រតិបត្តិករ រដ្ឋបាល អ្នកធានា អាណាព្យាបាល ឬមេធាវី
- អ្នកធានាការចូលបំពេញការងាររបស់អតិថិជន (ដើម្បីបញ្ជាក់ពីព័ត៌មានលំអិតរបស់អតិថិជន)
- អង្គភាពត្រួតពិនិត្យ និងទីភ្នាក់ងាររដ្ឋាភិបាល ក្នុងករណីដែលតម្រូវ ឬត្រូវបានអនុញ្ញាត
- ទីភ្នាក់ងាររាយការណ៍ឥណទាន

- ស្ថាប័នហិរញ្ញវត្ថុ និងអង្គភាពដទៃទៀត ដែលអតិថិជនបានស្វែងរកឥណទានពីពួកគេ (តាមការស្នើសុំរបស់ពួកគេ ដូច្នេះគេអាចវាយតម្លៃដើម្បីផ្តល់ឥណទានជូនអតិថិជន) និង
- អង្គភាពដទៃទៀតដែលបានជួយ COMMO T ក្នុងការផ្តល់ផលិតផល និងសេវាកម្ម ដោយបំពេញមុខងារ ដូចជាទំនាក់ទំនងអតិថិជន ធនាគារ ការទូទាត់ ការដំណើរការទិន្នន័យ ការស្តារបំណុល ទីផ្សារ និងការផ្សព្វផ្សាយ ការវិភាគទិន្នន័យ អាជីវកម្មឆ្លាតវៃ សេវាកម្មគេហទំព័រ និងបច្ចេកវិទ្យា។ ពួកគេក៏អាចផ្តល់ផលិតផល និងសេវាកម្មដែលរួមបញ្ចូល ឬបំពេញនូវផលិតផល និងសេវាកម្មរបស់ COMMO T ផងដែរ។

COMMO T មានភារកិច្ចក្នុងការការពារព័ត៌មានរបស់អតិថិជនយ៉ាងម៉ឺងម៉ាត់បំផុត និងខិតខំប្រឹងប្រែងក្នុងការដោះស្រាយតែជាមួយភាគីដែលបានចែករំលែក និងបង្ហាញអាកប្បកិរិយាដូចគ្នាក្នុងការរក្សាការសម្ងាត់របស់អតិថិជន។ តតិយភាគីនីមួយៗដែល COMMO T បានទាក់ទងជាមួយ គឺត្រូវបានជ្រើសរើសយ៉ាងយកចិត្តទុកដាក់បំផុត និងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន តាមរបៀបដែលមានសុវត្ថិភាព ដែលចាំបាច់សម្រាប់ការអនុវត្តសេវាកម្មរបស់ពួកគេទៅ COMMO T។ ហើយ COMMO T នឹងបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន ប្រសិនបើ COMMO T ត្រូវបានតម្រូវដោយច្បាប់ ឬត្រូវបានអនុញ្ញាត។

ក្រុមហ៊ុន និងតតិយភាគីមួយចំនួនរបស់ COMMO T ដែលបានចែករំលែកព័ត៌មានជាមួយ អាចមានទីតាំងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ COMMO T នឹងបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន ទៅកាន់អ្នកទទួលនៅក្រៅប្រទេសក្នុងករណីដែល COMMO T បានអនុវត្តតាមកិច្ចសន្យាសមស្រប និងបានអនុវត្តតាមជំហានជាក់ស្តែងដើម្បីធានាថា៖

- អ្នកទទួលនៅបរទេសមិនរំលោភលើគោលនយោបាយនេះ
- អតិថិជនអាចធ្វើសកម្មភាព ដើម្បីពង្រឹងការការពារច្បាប់ ឬគ្រោងការណ៍ដែលមានប្រសិទ្ធិភាពក្នុងការការពារព័ត៌មានតាមរបៀបមួយដែលមានលក្ខណៈប្រហាក់ប្រហែលនឹងនីតិវិធី ដែលគោលនយោបាយស្តីពីឯកជនភាពការពារព័ត៌មានទាំងនោះ
- អតិថិជនបានផ្តល់ការព្រមព្រៀង សម្រាប់ការបង្ហាញបន្ទាប់ពី COMMO T បានបង្ហាញអតិថិជនយ៉ាងច្បាស់ថា មិនមានការធានាថាអ្នកទទួលនៅបរទេសនឹងមិនរំលោភបំពានលើសិទ្ធិឯកជននេះឡើយ
- ការបង្ហាញព័ត៌មានត្រូវបានតម្រូវ និងត្រូវបានអនុញ្ញាតដោយច្បាប់ បទប្បញ្ញត្តិ ឬបទបញ្ជារបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា
- ស្ថានភាពទូទៅដែលត្រូវបានអនុញ្ញាត ដែលទាក់ទងទៅនឹងការបង្ហាញនៃព័ត៌មាន។

## សុវត្ថិភាពនៃព័ត៌មានផ្ទាល់ខ្លួនបុគ្គល

រាល់ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនដែលបានផ្តល់ឱ្យ COMMO T នឹងត្រូវចាត់ទុកជាការសម្ងាត់ និងត្រូវបានចែករំលែកតែជាមួយ COMMO T និងដៃគូពាក់ព័ន្ធ ហើយមិនបង្ហាញទៅកាន់តតិយភាគីណាផ្សេងទៀតឡើង លើកលែងតែស្ថិតក្រោមនីតិវិធីនៃបទប្បញ្ញត្តិ ឬគោលការណ៍ច្បាប់ណាមួយតែប៉ុណ្ណោះ។ ព័ត៌មានផ្ទាល់ខ្លួនដែលអតិថិជនបានផ្តល់ពាក់ព័ន្ធនឹងការចុះឈ្មោះជាអ្នកប្រើប្រាស់របស់ COMMO T ត្រូវបានការពារជាច្រើនដំណាក់កាល។ អតិថិជនអាចចូលទៅកាន់ព័ត៌មានចុះឈ្មោះរបស់ខ្លួន តាមរយៈលេខកូដសម្ងាត់ដែលបានជ្រើសរើសដោយអតិថិជនផ្ទាល់។ លេខកូដសម្ងាត់នេះ ត្រូវបានការពារ (encrypted) និងដឹងតែអតិថិជនម្នាក់តែប៉ុណ្ណោះ ហើយមិនត្រូវបង្ហាញទៅកាន់អ្នកដទៃនោះទេ។ ព័ត៌មានអំពីការចុះឈ្មោះ ត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាពនៅក្នុងប្រព័ន្ធ ដែលមានតែបុគ្គលដែលមានការអនុញ្ញាតទេទើបអាចប្រើប្រាស់លេខកូដសម្ងាត់បាន។ COMMO T បានការពារ (encrypt) រាល់ព័ត៌មានផ្ទាល់ខ្លួនបុគ្គលទាំងអស់ ព្រោះវាត្រូវបានផ្ទេរទៅកាន់ COMMO T ដូច្នេះ ក្រុមហ៊ុនបានប្រឹងប្រែងជាចាំបាច់ក្នុងការការពាររាល់ភាគីដែលគ្មានការអនុញ្ញាតពីការមើលព័ត៌មានទាំងនោះ។

## គុណភាពនៃព័ត៌មានផ្ទាល់ខ្លួនបុគ្គល

COMMO T ធានាថាព័ត៌មានផ្ទាល់ខ្លួនបុគ្គលដែល COMMO T បានប្រមូល និងគ្រប់គ្រងដោយត្រឹមត្រូវ មានបច្ចុប្បន្នភាព ពេញលេញ និងសមស្រប។ COMMO T អាចចាត់វិធានការដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួនបុគ្គល ដែល COMMO T បានកាន់កាប់។ សូមមេត្តាទាក់ទងមកកាន់ COMMO T ក្នុងករណីដែលព័ត៌មាន ឬទិន្នន័យដែលអតិថិជនបានផ្តល់ឱ្យ COMMO T មានការប្រែប្រួល ឬអតិថិជនជឿជាក់ថាព័ត៌មានដែល COMMO T មានទាំងនោះ មិនត្រឹមត្រូវ ឬមិនបានធ្វើបច្ចុប្បន្នភាព។

## សុវត្ថិភាពនៃព័ត៌មានផ្ទាល់ខ្លួនបុគ្គល

COMMO T ប្តេជ្ញាការពារព័ត៌មានផ្ទាល់ខ្លួនបុគ្គលដែល COMMO T ទទួលបានពីអតិថិជនពីការប្រើប្រាស់ដោយមិនត្រឹមត្រូវ ចំគោលដៅដោយគ្មានការអនុញ្ញាតក្នុងការប្រើប្រាស់ និងបង្ហាញ។ COMMO T បានដាក់ដំណើរការនូវការអនុវត្ត និងគោលនយោបាយ ដើម្បីផ្តល់នូវបរិយាកាសសុវត្ថិភាពរឹងមាំ។ COMMO T ធានាបាននូវគុណភាពនៃវិធានការទាំងនេះ តាមរយៈការត្រួតពិនិត្យសារឡើងវិញយ៉ាងទៀងទាត់។

វិធានការសុវត្ថិភាពរបស់ COMMO T រួមមាន÷

- ការអប់រំនិយោជិតរបស់ COMMO T អំពីកាតព្វកិច្ចរបស់និយោជិត នៅពេលប្រមូល និងគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន
- តម្រូវឱ្យនិយោជិតរបស់ COMMO T ប្រើប្រាស់លេខកូដសម្ងាត់នៅពេលចូលប្រើប្រាស់ប្រព័ន្ធរបស់ COMMO T
- ការពារទិន្នន័យដែលបានផ្ញើពីកុំព្យូទ័ររបស់អតិថិជន ទៅកាន់ប្រព័ន្ធរបស់ COMMO T ក្នុងអំឡុងពេលប្រតិបត្តិការតាមអ៊ីនធឺណេត និងប្រប្រាស់លេខកូដរបស់អតិថិជន នៅពេលបញ្ជូនឆ្លងកាត់តាមបណ្តាញ
- ការប្រើប្រាស់ការការពារ (Firewalls) ប្រព័ន្ធរាវរកការឈ្លានពាន និងកម្មវិធីកម្ចាត់មេរោគ ដើម្បីការពារការចូលក្នុងប្រព័ន្ធរបស់ COMMO T ដោយមនុស្ស ឬមេរោគកុំព្យូទ័រ ដោយគ្មានការអនុញ្ញាតិ
- ប្រើប្រាស់បណ្តាញសុវត្ថិភាព ឬការការពារ (Encryption) នៅពេលដែល COMMO T បញ្ជូនទិន្នន័យអេឡិចត្រូនិចសម្រាប់គោលបំណងនៃការបំពេញការងារក្រៅក្រុមហ៊ុនដោយតតិយភាគី
- អនុវត្តគោលនយោបាយតុទំនេរ សម្រាប់គ្រប់ទីកន្លែង និងផ្តល់កន្លែងផ្ទុកដែលមានសុវត្ថិភាពសម្រាប់កំណត់ត្រារូបវន្ត និង
- ការប្រើប្រាស់វិធានការសន្តិសុខរូបវន្ត និងអេឡិចត្រូនិច ដូចជាកាតអូស (Swipe Cards) ឧបករណ៍រោទិ៍ កាមេរ៉ាសុវត្ថិភាព និងសន្តិសុខយាមកាម (តាមតម្រូវការ) ដើម្បីការពារពីការចូលទៅក្នុងអគារដោយគ្មានការអនុញ្ញាត។

នៅពេលដែល COMMO T កំណត់ថា COMMO T លែងត្រូវការព័ត៌មានផ្ទាល់ខ្លួនបុគ្គលទាំងនោះទៀត COMMO T នឹងធានាថាព័ត៌មានទាំងនោះត្រូវបានបំផ្លាញប្រកបដោយប្រសិទ្ធិភាព និងសុវត្ថិភាពខ្ពស់។ ឯកជនភាព និងការសម្ងាត់របស់ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនមានសារៈសំខាន់ជាមូលដ្ឋានដល់ COMMO T។ COMMO T នឹងចាត់វិធានការសមស្របទាំងអស់ដើម្បីការពារប្រឆាំងនឹងការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬការផ្លាស់ប្តូរដោយគ្មានការអនុញ្ញាត ទៅលើការបង្ហាញ ឬការបំផ្លាញទិន្នន័យ និងព័ត៌មានផ្ទាល់ខ្លួនបុគ្គល។ COMMO T ហាមឃាត់ការទទួលបានព័ត៌មានផ្ទាល់ខ្លួនដល់និយោជិត ដែលត្រូវការដឹងព័ត៌មានជាក់លាក់ដើម្បីធ្វើប្រតិបត្តិការ អភិវឌ្ឍ ឬកែលម្អសេវាកម្មរបស់ COMMO T។ បុគ្គលទាំងនោះ ត្រូវបានចងភ្ជាប់ដោយការសម្ងាត់ និងត្រូវទទួលទណ្ឌកម្ម ក្នុងករណីដែលពួកគេមិនបានបំពេញតាមកាតព្វកិច្ចដែលតម្រូវទាំងនោះ។

## សិទ្ធិក្នុងការទទួលបាន ឬកែប្រែព័ត៌មានផ្ទាល់ខ្លួនបុគ្គល

1. ប្រសិនបើអតិថិជនបានផ្តល់ព័ត៌មានផ្ទាល់ខ្លួនមកកាន់ COMMOT អតិថិជនមានសិទ្ធិក្នុងការស្នើសុំដើម្បីទទួលបាន ឬកែប្រែ។

2. ការស្នើសុំដើម្បីទទួលបាន ឬកែប្រែព័ត៌មានផ្ទាល់ខ្លួនមានការកំរិត ដូចជាការត្រួតពិនិត្យដើម្បីមើលអាស័យដ្ឋាន ឬលេខទូរស័ព្ទ COMMO T បាតកត់ត្រា ជាទូទៅអាចធ្វើការគ្រប់គ្រងបានតាមរយៈទូរស័ព្ទ។
3. COMMO T នឹងឆ្លើយតបទៅកាន់ការស្នើសុំរបស់អតិថិជន ឱ្យបានឆាប់តាមដែល COMMO T អាចធ្វើបាន។ ក្នុងករណីខ្លះ COMMO T នឹងតម្រូវឱ្យអតិថិជនធ្វើការបង់ថ្លៃរដ្ឋបាល ដើម្បីទូទាត់ការចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងសំណើររបស់អតិថិជន។ COMMO T នឹងបញ្ជាក់ពីកម្រៃសេវាជាមួយនឹងអតិថិជន ហើយបញ្ជាក់ពីការព្រមព្រៀងរបស់អតិថិជនមុននឹងបន្តទៅមុខ។
4. COMMO T នឹងព្យាយាមអនុវត្តតាមការស្នើសុំរបស់អតិថិជនក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីទទួលបានសំណើរពីអតិថិជន។ ដើម្បីសម្រួលដល់ការឆ្លើយតបរបស់ COMMO T សូមបញ្ចូលព័ត៌មានលំអិតតាមដែលអាចធ្វើទៅបាន អំពីព័ត៌មានដែលអតិថិជនចង់ទទួលបាន ឬកែប្រែ ហើយប្រសិនបើពាក់ព័ន្ធ សូមកំណត់ពីវិធីក្នុងការទទួលបានព័ត៌មានដែលអតិថិជនចង់ទទួលបាន។
5. COMMO T នឹងបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជនមុនពេលដែលផ្តល់ជូននូវការទទួលបានព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន។

## ការលើកលែង និងការបដិសេធក្នុងការមិនផ្តល់សិទ្ធិក្នុងការប្រើប្រាស់ ឬកែប្រែ

ក្នុងកាលៈទេសៈមួយចំនួន COMMO T អាចត្រូវបដិសេធសំណើររបស់អតិថិជន ក្នុងការទទួលបាន ឬកែប្រែ ឬកំណត់ការទទួលបានដែលនឹងផ្តល់ជូនដោយ COMMO T។ នៅក្នុងស្ថានភាពនេះ COMMO T នឹងផ្តល់ដំណឹងអំពីមូលហេតុនៃការសម្រេចចិត្តរបស់ COMMO T ជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអតិថិជនមិនយល់ស្របជាមួយនឹងការសម្រេចចិត្តរបស់ COMMO T អតិថិជនអាចធ្វើការបណ្តឹងតវ៉ាតាមនីតិវិធីដែលបានកំណត់។

## កម្រិតនៃការទទួលខុសត្រូវ

COMMO T មិនទទួលខុសត្រូវលើគោលនយោបាយស្តីពីឯកជនភាព ឬមាតិកានៃគេហទំព័ររបស់ COMMO T ដែលភ្ជាប់ទៅ និងគ្មានការគ្រប់គ្រងលើការប្រើប្រាស់ ឬការពារព័ត៌មានដែលបានផ្តល់ឱ្យដោយអតិថិជន ឬប្រមូលដោយគេហទំព័រទាំងនោះទេ។ នៅពេលដែលអតិថិជនបានជ្រើសរើសការភ្ជាប់ទៅកាន់គេហទំព័រនោះ អតិថិជនអាចត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានពីការចុះឈ្មោះ ឬព័ត៌មានផ្សេងទៀត។ សូមកត់សម្គាល់ថា ព័ត៌មានទាំងនោះនឹងត្រូវបានកត់ត្រាដោយតតិយភាគី ហើយត្រូវបានគ្រប់គ្រងដោយគោលនយោបាយស្តីពីឯកជនភាពរបស់តតិយភាគីនោះ។

## វិសោធនកម្មនៃគោលនយោបាយស្តីពីឯកជនភាព

COMMO T រក្សាសិទ្ធិក្នុងការកែប្រែ ឬធ្វើវិសោធនកម្មទៅលើគោលនយោបាយនេះ ដោយមិនចាំបាច់ជូនដំណឹងជាមុនដល់អតិថិជន ដោយមិនមានការកែប្រែ ឬកាត់បន្ថយសិទ្ធិយ៉ាងខ្លាំងរបស់អតិថិជនតាមរយៈគោលនយោបាយនេះទេ។ ក្នុងករណីដែល COMMO T ធ្វើការកែប្រែសំខាន់ៗទៅលើគោលនយោបាយនេះ រួមបញ្ចូលនូវការប្រមូល ការដំណើរការ ឬការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន COMMO T នឹងធ្វើការជូនដំណឹងដល់អតិថិជនតាមរយៈសារអេឡិចត្រូនិច ឬតាមរយៈការជូនដំណឹងនៅលើគេហទំព័ររបស់ COMMO T។ អតិថិជនបានយល់ព្រមទទួលយកការដាក់បញ្ចូល នូវគោលនយោបាយស្តីពីឯកជនភាពដែលបានធ្វើការកែប្រែជាអេឡិចត្រូនិច នៅលើគេហទំព័រដែលបានជូនដំណឹងផ្ទាល់ទៅកាន់អតិថិជន។ រាលវិវាទដែលកើតមានឡើងចំពោះ គោលនយោបាយស្តីពីឯកជនភាពរបស់ COMMO T គឺអាស្រ័យលើសេចក្តីជូនដំណឹងនេះ និងកិច្ចព្រមព្រៀងរបសអតិថិជនរបស់ COMMO T។ COMMO T លើកទឹកចិត្តឱ្យអតិថិជនឧស្សាហ៍ត្រួតពិនិត្យឡើងវិញនូវគោលនយោបាយនេះ ដើម្បីឱ្យអតិថិជនដឹងពីការប្រមូលព័ត៌មាន ការប្រើប្រាស់ និងការបង្ហាញព័ត៌មានតាមរយៈ COMMO T។ គោលនយោបាយនេះ នឹងមានគ្រប់ពេលនៅលើគេហទំព័រ commot.asia.

# ការមិនទទួលខុសត្រូវផ្លូវច្បាប់

COMMO T រក្សាសិទ្ធិក្នុងការបង្ហាញព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់អតិថិជន ដែលតម្រូវដោយច្បាប់ បទប្បញ្ញត្តិ ការអនុវត្តច្បាប់ ឬសិទ្ធិអំណាចរបស់អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៃយុត្តាធិការ និងនៅពេលដែល COMMO T យល់ឃើញពីការចាំបាច់នៃការបង្ហាញដើម្បីការពារសិទ្ធិរបស់ COMMO T និង/ឬដើម្បីអនុវត្តតាមនីតិវិធីតុលាការ សាលក្រម ឬសាលដីកាតុលាការ ឬដំណើរការតាមផ្លូវច្បាប់។ COMMO T មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ខុសគោលដៅ ឬការបាត់បង់ព័ត៌មានផ្ទាល់ខ្លួនបុគ្គល ដែលបណ្តាលមកពី Cookies ដែលមាននៅលើគេហទំព័ររបស់ COMMO T ដែល COMMO T គ្មានសិទ្ធិក្នុងការចូល ឬគ្រប់គ្រងនោះទេ។ COMMO T មិនទទួលខុសត្រូវលើការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនបុគ្គលដោយខុសច្បាប់ ឬដោយគ្មានការអនុញ្ញាតពីអតិថិជន តាមរយៈការប្រើប្រាស់ខុស និងការរក្សាទុកមិនបានត្រឹមត្រូវនូវលេខកូដសម្ងាត់របស់អតិថិជន ការធ្វេសប្រហែស ឬដោយសារមេរោគនៅក្នុងកុំព្យូទ័ររបស់អតិថិជននោះទេ។

# ការព្រមព្រៀង

អតិថិជនបានអាន យល់ច្បាស់ និងយល់ព្រមទទួលយកតាមលក្ខខណ្ឌនៃគោលនយោបាយនេះ ហើយអតិថិជនសូមបញ្ជាក់ថា អតិថិជនមានអំណាច និងសិទ្ធិពេញលេញដែលត្រូវគោរពតាមលក្ខខណ្ឌនៃគោលនយោបាយនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់យើងខ្ញុំតាមរយៈសារអេឡិចត្រូនិច info@commot.asia ៕